00636049

E14

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោកស្រី អៀង ធីរិទ្ធ និង លោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី១៤ ខែមករា ឆ្នាំ ២០១១

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ សាធារណៈ / Public

ចំណាត់ថ្នាក់ឯកសារដោយ កសចស

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើបន្ទាន់របស់មេធាវីការពារក្ដីសុំឲ្យបញ្ជាក់ពីថ្ងៃកំណត់**

---

ដាក់ដោយ៖

**ក្រុមមេធាវីការពារក្ដី អៀង ធីរិទ្ធ:**

ផាត់ ពៅសៀង

Diana ELLIS, QC

**ក្រុមមេធាវីការពារក្ដី នួន ជា:**

សុន អរុណ

Michiel PESTMAN

Victor KOPPE

ផ្ញើជូន៖

**ចៅក្រមសាលាដំបូង**

ចៅក្រម និល ណុន, ប្រធាន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យូ អុតតារ៉ា

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យ៉ា សុខន

**សហព្រះរាជអាជ្ញា**

លោកស្រី **ជា លាង**

លោក Andrew CAYLEY

**មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី និង**

**ដើមបណ្ដឹងរដ្ឋប្បវេណីគ្មានតំណាង**

**ឯកសារទទួល**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 14 / 01 / 2011
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

## I. សេចក្តីផ្តើម

១. ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ការិយាល័យសហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយ[1] ដែលត្រូវបានប្តឹងឧទ្ធរណ៍ដោយមេធាវីការពារក្តីរបស់លោកស្រី អៀង ធីរិទ្ធ និង លោក នួន ជា ("បណ្តឹងឧទ្ធរណ៍")[2]។ នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ អង្គបុរេជំនុំជម្រះ ("អបជ")បានចេញ "សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ" ("សាលដីកាលើបណ្តឹងឧទ្ធរណ៍")[3] ។

២. សាលដីកាលើបណ្តឹងឧទ្ធរណ៍មានសេចក្តីសន្និដ្ឋានសេចក្តីសម្រេច ប៉ុន្តែមិនបានបញ្ជាក់ពីមូលហេតុ ។ មេធាវីការពារក្តីនឹងដាក់ជូនថា ពេលវេលាកំណត់ចាប់ផ្តើមពីពេលចេញដីកាដំណោះស្រាយ និង មិនចាប់ផ្តើមនៅមុនពេលហេតុផលនៃសេចក្តីសម្រេចត្រូវបានផ្តល់ជូនទៅភាគី ដោយអនុលោម តាមវិធាន ៧៧(១៤) នៃវិធានផ្ទៃក្នុង។

## II. សារណា

៣. សាលដីកាលើបណ្តឹងឧទ្ធរណ៍ បញ្ជាក់ថា "អង្គបុរេជំនុំជម្រះបានសម្រេចជាស្ថាពរលើបណ្តឹង ឧទ្ធរណ៍ ដូចដែលអង្គបុរេជំនុំជម្រះប្រកាសនៅពេលនេះ។ ការចេញសំអាងហេតុសម្រាប់គាំទ្រ សាលដីកានេះ នឹងធ្វើទៅតាមពេលវេលាសមស្រប"[4]។

៤. វិធាន៨០ ផ្តល់កាលកំណត់សម្រាប់ដាក់បញ្ជីឈ្មោះសាក្សី។ វិធាន ៨៩ ផ្តល់កាលកំណត់សម្រាប់ ការលើកឡើងពីអញ្ញត្រកម្ម។ កាលកំណត់ទាំងពីរចាប់ផ្តើមពីថ្ងៃដែលដីកាដំណោះស្រាយចូលជា ស្ថាពរ។ ខណៈដែលពាក្យនៃសាលដីកាលើបណ្តឹងឧទ្ធរណ៍ បង្ហាញថា ដីកាដំណោះស្រាយចូលជា ស្ថាពរដោយសារសាលដីកាលើបណ្តឹងឧទ្ធរណ៍ មេធាវីការពារក្តីសូមលើកឡើងថា ដីកាដំណោះ ស្រាយចូលជាស្ថាពរដរាបណាអង្គបុរេជំនុំជម្រះចេញសំអាងហេតុសម្រាប់គាំទ្រសាលដីកា។

៥. វិធាន ៧៧ នៃវិធានផ្ទៃក្នុងបញ្ជាក់ពីនីតិវិធីសម្រាប់បណ្តឹងឧទ្ធរណ៍ និងពាក្យសុំទៅអង្គបុរេជំនុំ

---

[1] ឯកសារលេខ D427 "ដីកាដំណោះស្រាយ" ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០។

[2] D427/2/1 "បណ្តឹងឧទ្ធរណ៍ អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ" ថ្ងៃទី១៨ តុលា ឆ្នាំ២០១០។ D427/3/1 "បណ្តឹងឧទ្ធរណ៍ នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ" ថ្ងៃទី១៨ តុលា ឆ្នាំ២០១០។

[3] D427/2/12 "សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ"។

[4] សាលដីកាលើបណ្តឹងឧទ្ធរណ៍ ទំព័រ៥។

ជម្រះ ដូចដែលមានក្នុងវិធាន ៧៧ (១៤) ថា៖

"សេចក្ដីសម្រេចទាំងអស់ស្ថិតក្នុងវិធាននេះ [...] ត្រូវមានសំអាងហេតុ [...]"

អាស្រ័យហេតុនេះហើយ សេចក្ដីសម្រេចនេះ មិនអាចចាត់ទុកថាជា "សេចក្ដីសម្រេច" បានទេនៅក្រោមវិធាន លុះត្រាតែ និងរហូតដល់មានសំអាងហេតុ។ ដូចនេះទាល់តែមានសំអាងហេតុគាំទ្រសាលដីកាលើបណ្ដឹងឧទ្ធរណ៍នេះ ទើបអាចក្លាយជា "សេចក្ដីសម្រេច"។

៦. អនុលោមតាមវិធាន ៨០(២) ការស្រង់បញ្ជីឈ្មោះសាក្សី និងការលើកឡើងពីអញ្ញត្រកម្ម តាមវិធាន ៨៩(១) តម្រូវឱ្យមេធាវីការពារក្ដីដឹងពីសំអាងហេតុផ្អែកលើអ្វីដែល អបជ បានធ្វើសេចក្ដីសម្រេចរបស់ខ្លួន។ មេធាវីការពារក្ដីសូមលើកឡើងថា វានឹងធ្វើឱ្យប៉ះពាល់ ប្រសិនបើតម្រូវឱ្យបង្កើតអញ្ញត្រកម្មយុត្តាធិការដោយពុំបានដឹងពីសំអាងហេតុរបស់ អបជ ចំពោះបញ្ហាជាក់លាក់នេះ។ ដូចគ្នានេះដែរ វានឹងប៉ះពាល់ដល់មេធាវីការពារក្ដី ដែលត្រូវបានតម្រូវឱ្យផ្ដល់បញ្ជីសាក្សីដោយពុំបានដឹងពីការបញ្ជាក់សំអាងហេតុចំពោះដីកាបញ្ជូនរឿងទៅជំនុំជម្រះជាស្ថាពរ។

៧. ការតម្រូវឱ្យមេធាវីការពារក្ដីធ្វើដូច្នេះ នឹងជាការរំលោភលើមាត្រា ១៤(៣) នៃអនុសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋនិងនយោបាយ (ICCPR) ដែលបានធានាដល់ជនជាប់ចោទនូវសិទ្ធិ "(ក) ត្រូវបានពត៌មានភ្លាមៗ និងដោយលំអិត [...] អំពីប្រភេទ និងមូលហេតុ នៃការចោទប្រកាន់មកលើខ្លួន" និង "(ខ) មានពេលវេលា និងសម្ភារៈរូបវ័ន្តគ្រប់គ្រាន់ សម្រាប់រៀបចំការការពារខ្លួន [...]"។

## III. សេចក្ដីសន្និដ្ឋាន

៨. មេធាវីការពារក្ដីសូមស្នើដោយគោរពដល់អង្គជំនុំជម្រះសាលាដំបូងបញ្ជាក់ថា ពេលវេលាកំណត់នៅក្រោមវិធាន ៨០ និង ៨៩, និងទីពីរ ចេញដីកាថាពេលវេលាកំណត់នេះ គឺចាប់ផ្ដើមពីថ្ងៃដែល អបជ បានចេញសំអាងហេតុគាំទ្រដល់សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ខ្លួន។ ដោយពិចារណាលើសារធាតុសំណើនេះ មេធាវីការពារក្ដីសូមស្នើដោយគោរពដល់ អជសជ ចេញដីកាលើបញ្ហានេះឱ្យបានឆាប់តាមដែលអាចធ្វើបាន។

| ភាគី | កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|---|
| សហមេធាវីរបស់លោកស្រី អៀង ធីរិទ្ធ | ១៤មករា ២០១១ | ផាត់ ពៅស៊ាង<br>Diana ELLIS, QC | ភ្នំពេញ | P.P. |
| សហមេធាវីរបស់លោក នួន ជា | ១៤មករា ២០១១ | សុន អរុណ<br>Michiel Pestman & Victor Koppe | ភ្នំពេញ | P.P. |